Conseil Ta Meas

រឿងបណ្ដាំតាមាស

# រឿងបណ្ដាំតាមាស

១ តាមខ្ញុំឈ្មោះម៉ាស ជាចាស់ព្រឹទ្ធាចារ្យ អាយុស្មើជាង ៨០ ឆ្នាំហើយ កើតក្នុងឆ្នាំជូតសំរិទ្ធស័ក្យ ចុលស័ករាជ ១១៩០ បើគិតជាស័ករាជបារាំង ត្រូវថែមឡើក ១ ទៀត ទើបត្រូវនិង ឆ្នាំ ១៨២៨ តែងជាពាក្យបណ្ដាំនេះទុក ឲ្យកូនចៅនៅឯក្រោយ ចូលចាំមគ្រប់គ្នា ផ្សាយប្រាប់គ្នាតៗទៅ

កាលដើមឡើយអាពុកខ្ញុំ ធ្វើជាបាឡាត់ខែត្រលង្វែក ជាខែត្រដែរ កាលនោះជីតាខ្ញុំធ្វើចៅហ្វាយស្រុក នោះខ្ញុំទាន់ជីតាខ្ញុំ គាត់ច្បាំងនិងយួន កាលរាជហ្លួងអង្គមី ហើយគាត់បាត់បង់ក្នុងទ័ព តមកទៀតអាពុកខ្ញុំ គាត់តាមកងទ័ពទៅដេញយួន ៗ ក៏បាក់រត់ខ្ចាត់ខ្ចាយទៅគ្រប់ទិស ឯខ្លួនគាត់ក៏បាត់មិនដឹងជាទៅឯណា មិនឃើញគាត់ត្រឡប់មកផ្ទះវិញ ជីដូនខ្ញុំគាត់បាត់បង់

ជាង ១១ ឆ្នាំ ១២ ឆ្នាំ មុនជីតាខ្ញុំ នៅកណ្ដាលផ្លូវដែរទៅពី បាត់ដំបងទៅបាងកក ដ្បិទកាលណោះពួកកងទាព់សៀម កៀរគាត់ តាំមទៅជាឈ្លើយ ឯម្ដាយខ្ញុំគាត់បាត់បង់ នៅវេលាដែរយួនលើក មកលុកប្លន់បន្ទាយណង្វែក បងប្អូនប្រុសខ្ញុំ ៣ នាក់ អនិច្ចកម្ម ក្នុងទីបំម្បាំង កាលណោះទៅច្បាំងជាមួយនិងមាគាត់ ២ នាក់ ហើយ និងបងប្អូនជីដូនមួយច្រើននាក់ ដែរតាំមពួកកងទាព់ស្រុះបិត្រ គ្នាទៅច្បាំង ឯខ្លួនខ្ញុំបួលច្បាំងនិងគេបាន ៣ ឆ្នាំ ដំរាំបទាល់ តែស្រុកសានត្រាន ហើយបង្ហូងអង្គខ្លងបុះសត្យ៉ា ធ្វើជាស្ពាន មេត្រីនិងសៀមនិងយួន

នៅវេលានោះខ្ញុំក៏ធំមមានអាយុស្មឹក្រែល លួមឃើញ ស្គាល់ហាំមការត្រូប់ជុំពួកបាន ហើយបានយល់ច្បាស់ដែរពួក តាមុីន ៗ គេឲ្យវាយគ្នានៅប្រែបខ្ញុំ ៗ ហាំមបានទាំងអស់

ស្រុកកាលណោះបាក់បែកក្រេរទាល់ក្នុងមួយភូម ៗ រកព្រិក មួយផ្ទៀលគ្នាន រត់បោលស្រែបំការច្បាដំណាំមខានជាំមផ្លូវរាស់

ស្ទឹងត្រីសំសាប ព្រោះខ្លាចក្រែងយួនស៊ើប វាមកកំហែង ច្រូតយកស្រូវក្នុងស្រែ ដើមដូងដើមស្លា និងដើមឈើស៊ីផ្លែទាំងប៉ុន្មាន កាប់ចោលអស់ជាងពាក់កន្លះ ហើយក្នុងភូមដែលជិតៗ ដែលអាពុកខ្ញុំគាត់ធ្លាប់ឃើញស្គាល់ ពីដើមមានផ្ទះ ១៥០ នោះឃើញនៅតែផ្ទះ ៦០ ផ្ទះ ៥០ ផ្ទះ ២៥ វិញ ឯរាស្ត្របំណុះស្រុក ក៏តិចជាងពីដើម ពួកសមណៈជីព្រាហ្មណ៍កើតទុក្ខវេទនា ព្រោះវាលុកប្លន់ព្រះវិហារវ៉ាម ជន្ទួនយកព្រះពុទ្ធរូបណាដែរជាមាស ជាប្រាក់ ជាសំរិទ្ធ ហើយវាដុតព្រះវិហារវត្តអារ៉ាមជាច្រើនអន្លើបាំ វត្តណាដែរនៅសល់នោះរកជីបួលគ្មាន ជីបួលនោះស្រុតបាក់ ធ្លាក់ទៅគ្របលើអាសនៈព្រះ រកន៍ណានិងមានចិត្តគិតជួសជុលគ្មាន ព្រោះរវល់តែនិងច្បាំងរាំងជល់រៀងមកជាប់ ៥០ ឆ្នាំ ស្រុកភូមបាក់បែក រត់ចោលស្ងាត់ស្លុតឈឹង មុខគួរឲ្យស្រងែះស្រងោចខ្លោចផ្សាណាស់ ណាវេទនានិងស្រី ដែលមានកូនតូច ៗ អង្គុយឱបក្បាលជង្គង់ មុខប្រមិសមើលតែមុខកូនភ្លឹះ ៗ

លុះបានស្រុកសានត្រាន បានចុះសន្យាជាស្ពានមេត្រី នោះហ្លួងអង្គឌួង បានស្នោយរាជជាស្ដេចហើយ នោះរាស្ត្ររាល់គ្នាគ្រាន់មានចិត្តសង្ឃឹម ហើយគេអឺរាយសរសើរថាស្ដេចល្អទ្រង់ធម៌ ព្រះទៃ្យសប្បុរស់ជ្រះថ្លាជឹងអធ្យោកអធ្យាស្រ្ស័យ បុន្តែស្រុកយើងកាលនោះខ្សត់ណាស់ អស់អាណាប្រជានុរាស្ត្រលំបាកក្រៃពេកពន់ប្រមាណ បេះតែនៅទ្រាំមចាំមស្ងៀមពុំបានធ្វើការរកស៊ីអ្វីសោះ

ឯខ្លួនខ្ញុំកាលនោះក៏ក្រីក្រណាស់ ហើយគ្មានញាតិផៅសាច់សន្តានញៀតលានសោះ ឯចំណែះវិជ្ជាការក៏ឥតបិយ ស្គាល់តែសេចក្ដីទុក្ខសោកវេទនា ក៏មានចិត្តកាត់ជីវ្ហាសទ្ធាបង់បួស ស្រេចហើយក៏ចូលឧបសម្បទក្នុងសំណាក់ព្រះពុទ្ធសាសនា នៅក្នុងអារ៉ាម ១ ក្នុងក្រុងឱដុងមានជ័យ ដើម្បីនិងបានមគ្គផលទៅជាតិក្រោយកុំឲ្យអកុសលដូចជាតិនេះហើយនិងបានរៀនសូត្រធម៌អាត្ថស័ត្រាបាឡីផង រូបបុះប៉ៃមទាំងអកុសល ឯក្នុងវត្តសោតក៏រក

រៀនធម៌អាគមស័ត្រាបាឡី ភ្នួន ភ្លើងឆេះខូចអន្តរាយខ្លះ សៀមវា លួចយកខ្លះ យួនវាបំផ្លាញខូចខ្លះ ឯក្នុងវត្តប្រែប្រួលដែរទុំបួសភិក្ខុ នោះសោត ក៏មាននៅសល់តែលោកសង្ឃល្ងង់ខ្លៅ តុំមាន គិតរកស័ត្រាវិន័យ និងគម្ពីរព្រះអភិធម្មព្រះត្រៃបិដកឡើយ

ឯកើតច្បាំងក្នុងស្រុកខ្មែរ ហើយបុះសន្យាធ្វើស្ពានមេត្រីរួច ហើយ នោះពួកមហាស័ត្រូវយើងទាំងសង្ខាង គឺស្តេចសៀម ហើយ និងស្តេចយួន វានៅតែរួសយកដីយើងទៀត ឯស្តេចសៀម យកខែត្រពិណែកខាងជើង គឺស្រុកសៀមរាប មាននគរធំម ក្រុង ស្រុកខ្មែរយើង ហើយស្រុកបាត់ដំបង ម្លូរព្រៃ ទន្លេរពៅ ហើយនិង ខែត្រយើងខ្មែរទាំងបុន្មាន ដែរនៅមាត់ស្រមុទ ខាងទិសបាស្ចិម ឯស្តេចយួនយកដីដែនស្រុកខ្មែរទាំងបុន្មាន នៅខាងត្បូង គឺ ព្រៃនគរក្លួសាំងស៊ីនសព្វថ្ងៃនេះ រហូតទៅដល់ទល់និងព្រែកជីក ខែត្រពាមខាងឯឡិច ខាងឯកើត យករហូតទៅ ទន្លិមនិងក្រុង ភ្នំពេញ ។ ឯស្តេចម្ចាស់ផែន្ដីយើងលោកកើតទុក្ខព្រួយព្រះទ្បៃ ដូចជាវាស្នូដែរ ព្រោះទ្រង់ឈ្មោងយល់ថាសៀមហើយនិងយួន វា គិតយកស្រុកខ្មែរ បន្ទូលក្នុងស្រុកវារាល់គ្នា បុន្តែវាបន្ទូលមិនត្រាន់ បាន ព្រោះវាស័ត្រូវនិងគ្នា ហើយបែកគ្នាមិនកើត ដ្បិទវាចង់បាន តែទាំងអស់វាល់ខ្លួន ។ ម្ចាស់យើងលោកព្រួយព្រះទ្បៃ ១ ជុំពូក ទៀត ព្រោះសៀមវាចង់ទំនុកបំរុងលោក ។ តុំសព្វព្រះទ្បៃ ព្រោះវាមិនទុកលោកជាស្តេចផែន្ដីស្រុកខ្មែរ វាទុកលោកដូចជា ចៅហ្វាយស្រុកខ្មែរវិញ ឯយួនវាទុកលោកជាបំណុះវា ហេតុដូច្នេះ ព្រះអង្គក៏វិតតែព្រួយព្រះរាជហាវទ្បៃ ក្រែងកើតចំបាំងជាថ្មីទៀត ក្រែងស្រុកខ្មែរនិងវិនាសអន្តរាយ ហើយផុតមានអស់ពូជខ្មែរ ក្រែងនៅ តែសៀម ឬនៅតែខ្មែរដែរទុកសក់ប្លង់ពីក្រោយ ដូចជាត្លង់ស្មៀង យកកន្សែងជួតក្បាលដូចជាយួន

ឯហ្លួងយើងកាលើ្ហះលោកបែះតែខំមប្រឹងតាមការ ទ្រង់ បាត់ឲ្យបំឡុងស័ត្រាបាឡីប្ញាប់ទំលាប់ ហើយសុំបសួររកពង្សាវិជារ ដែលនៅសល់ឃើញទាំងបុន្មាន ឲ្យយកមកបំឡុងទុក ព្រោះ

ពេកកមានព្រះរាជហោរាវៃទ្យ ដើម្បីនិងរៀបចំស្រុកខ្មែរយើង ឲ្យរៀបរៀបរយ តែទ្រង់នៅមានព្រះរឹតុកក្រែងតទៅមុកសៀម ហើយនិងយួនវាយកស្រុកយើងខ្មែរបែកគ្នា ទ្រង់ព្រះបិន្ទាតែម្លេះ ទើបទ្រង់ឈ្វេងយល់ថា និងពិងរកស្រុកប្រទេសយ៉ូរុបណា ១ ឲ្យជួយទំនុកបំរុង ពិទ្យានិងទៅពិងបុស្ស៊ីអាំងក្លេស ព្រោះ អាំងក្លេសបានស្រុកភ្លឹង ហើយនិងស្រុកសឹង្គះបួរហើយ ពិទ្យា និងទៅពិងបុសរីឡាន្ទា ទ្រង់ពុំសព្វព្រះទ្យៃ ដ្បិតវីឡាន្ទាធ្វើជា បៅបញ្ឆេនៅស្រុកយ៉ាវ៉ា ស្រុកស្លូម៉ាត្រាហើយ ពិទ្យានិងទៅពិង បុស្ស៊ីអេះស្ប៉ាញ៉ុល ឬប៉ុទ្ទុកេស ដ្បិតសាស្ន៍ទាំងនោះពុំពូកែ ទ្រង់ ព្រះបិន្ទាតែម្លេះស្រេចហើយ ក៏ទ្រង់សំរេចថានិងពិងបារាំងសែស ដ្បិតបារាំងសែសគ្មានស្រុកបំណុះនៅប្រែបស្រុកខ្មែរ

១ ទៀតកាលពីដើមទ្រង់គង់នៅស្រុកបាងកក បានជួប និងបារាំងសែស ហើយទ្រង់ទតយល់រីករាយ មិនធ្មេងកន្ទ្រើង និងន៍ណាភាក់ទាក់រាប់អានអ្នកទាំងពួង ហើយបិត្រប្លើមក៏មានផុម្ភ

សប្បុរស ទើបទ្រង់សំរេចថាសុំមពិងបាភាំងសែស ឲ្យថ្វាយ ទំនុកបំរុង ការព្រះរាជស័ត្រូវយួននៅស្រុកព្រៃនគរ ហើយនិងការព្រះរាជស័ត្រូវសៀមជាដើម ព្រោះមានខាល្ងងមកឈរ អម ព្រះអង្គនៅស្រុកឧដុងមានជ្រៃ ទ្រង់មានព្រះទ្បៃអៀនខ្មាស ចង់ឲ្យរំឭតរូបពីផ្សៃសៀមនោះណាស់ ទើបទ្រង់តែងរាជទូត ២ នាក់ ឲ្យនាំមព្រះរាជសារ ទៅដល់កុងស៊ុលបារាំងសែស នៅស្រុកសឹង្គបុរី ១ ច្បាប់ទៀតទៅដល់អំម្ប៉ារ៉ស្តេចបារាំងសែស ក្នុងសេចក្តីព្រះរាជសារនោះ ថាសុំមពិងបុត្យស្តេចបារាំងសែស សុំមឲ្យស្តេចបារាំងសែស តែងរាជទូតចូលមកនិងបុះសញ្ញាគ្នា នោះស្តេចបារាំងសែស មិនឃើញតែងរាជទូតឲ្យមកបុះសញ្ញា ស្រាប់តែបាត់កងទាត់មកច្បាំងនិងស្តេចទេត្តា ស្រុកយួន ហើយវាយយកស្រុកព្រៃនគរ ហើយយកស្រុកក្លួសាំងស៊ីន បានពាក់កណ្តាលជាមុន ទើបយកពាក់កណ្តាលទៀត រៀងទៅទល់និងខែត្រពាម នោះហ្លួងក៏មានព្រះរាជហារវៃអំណារ ដោយសារ

ឃើញស្រុកបារាំងសែស លើកទ័ពមកច្បាំងជាមួយយួន កាល ព្លុងលុកគត់ ក្នុងឆ្នាំមមែឯកស័ក ចុល្លសករាជ ១២២០ ឆ្នាំ ។

គិតរំពឹងឃើញដំណើរទាំងនោះសព្វគ្រប់ទៅ ខ្ញុំមានចិត្ត អំណរនឹងបារាំងសែស ដែរមកជាមួយយួន វាជាសត្រូវនឹងយើង ខ្មែរ វាច្បាំងផ្តើមសង្កត់សង្កិនស្រុកយើង ពិតៗតែនឹង ៣០ ឆ្នាំ ហើយវាតាំងស្តេចស្រី ៗ បីព្រះអង្គ ១ ព្រះអង្គជាឯករាជ ១ អង្គជាទីឧបរាជ ១ អង្គទៀតជាទីព្រះកែវហ្វា ហើយវាធ្វើបន្ទាយរាយ ពេញតែស្រុកខ្មែរ បង្ខិតខ្មែរឲ្យធ្វើយោបាយស្រុក ឲ្យទុកសក់ ស្លៀកពាក់តាមសាសន៍វាជាយួន ហើយវាគិតផ្លាស់ឈ្មោះខេត្ត ស្រុកខ្មែរ ដាក់ឈ្មោះជាយួន ប៉ុន្តែនៅវេលានោះយើងខ្លបតែ បារាំងសែស កាលណាច្បាំងស្រុកយួនរួចហើយក៏ត្រឡប់ទៅស្រុកវិញ មិនមកជួយយើងខ្មែរ

ឯបារាំងសែស ដែរលើកទ័ពទៅច្បាំងនឹងស្តេចយួននោះ បើអ្នកទាំងឡាយ ពុំដឹងជាហេតុដើមទងដូចម្តេច នោះខ្ញុំនឹង អធិប្បាយរៀបរាប់ជូនស្តាប់ តាមដែរខ្ញុំបានដឹងឮគេនិយាយរាល់គ្នា នៅវេលាគ្រានោះ ជាកាលនោះប្រហែលជាង ១២០ ឆ្នាំ មកហើយ នោះក្តីស្តេចស្រុកយួនច្បាំងនឹងពួកក្បត់ ដែលគិតបាស់ ច្បាំងដណ្តើមយករាជស្រុកយួន ក៏កាលនោះមានពួកសេតាទាហ៊ានបារាំងសែស ហើយនឹងពួកកូប៉ាល់ចម្បាំងទាំងអស់ជាង ៤០០ នាក់ ចូលចិត្តយកអាសាធ្វើរាជការថ្វាយ ហើយច្បាំងនឹង ពួកក្បត់នោះយករាជថ្វាយវិញ ឯពួកបារាំងសែស ដែរប្រដៅ សាសនាគ្រិះស្តាំង ទៅអន្តងយកពួកសេតាទាហ៊ាន ទាំងនោះ មកជួយស្តេចស្រុកយួន ព្រោះតែពួកប្រដៅសាសនាទាំងនោះ មានចិត្តស្លូតត្រង់នឹងស្តេចយួន ធ្វើរាជការថ្វាយស្តេច ហើយអស់ អាណាប្រជានុរាស្ត្រយួន ក៏ស្រឡាញ់រាប់អានពួកប្រដៅសាសនា ទាំងនោះណាស់ ហើយមានរាស្ត្រយួនប្រុសស្រីជាច្រើន លែង បោលសាសន៍របស់ខ្លួន រត់ចូលសាសនាបារាំងសែស

ឯពួកសេតាទាហ៊ាន នឹងពួកបារាំងសែសទាំងប៉ុន្មាន ដែរ ពួកប្រដៅសាសនាបង្គាប់បញ្ជា នោះក៏មានចិត្តក្លាហាន ហើយតាម

ពួកកងទាត់ស្តេចយួនច្បាំងនិងពួកក្បថ ៗ ក៏អប្បរាជ័យចាញ់បាក់បបខ្ចបខ្ចប ហើយអ្នកស្តេចទេព្វយ៉ាឡុង ក៏បានឡើងសោយរាជជាស្តេចគ្រប់គ្រង មិនតែក្នុងបំណែកនគរយួន ហើយនិងស្រុកកូសាំងស៊ីនឡើយ ទាំងស្រុកតុងកឹង ក៏បានចូលមកក្នុងព្រះរាជអាណាចក្រទាំងអស់ ឯនគរស្តេចស្រុកយួនក៏បានធំមទូលាយឡើង ខាងឯជើងរហូតហួសស្រុកចិន្តទៀតទៅទល់និងស្រម៉ុទខាងកើត ដែរគេហៅស្រម៉ុទសៀម ពីខាងទិសនីរតី ទល់និងខែត្រពោម ឯនគរយួនកាល្នោះបំរើនធំមទូលាយជាងធម្មា

រីឯស្តេចយ៉ាឡុងជាស្តេចយួន នោះស្លាប់ក្នុងឆ្នាំថោះ ឯកស័ក្ស ស័ករាជ ១១៨១ ឆ្នាំ មានកូនប្រុស ១ ឈ្មោះមិញម៉ាង ឡើងសោយរាជត៍វង្ស ឈ្មោះស្តេចមិញម៉ាងនោះឯង ដែរចាត់កងទាត់យួនឲ្យមកច្បាំងនិងយើងខ្មែរ កាល្នោះជាចំម្បាំងធំមណាស់ នគរយើងខ្មែរនេះហៀបតែនិងបាត់ឲ្យយួន

ឯស្តេចយួននោះជាមនុស្សកុំណាច ប្រចណ្ឌនិត្តុលហ្មនិះ បែះតែរអៀសខ្លួន មិនទុកចិត្តន៍ណា ហើយតាំងធ្វើទុក្ខបុកម្នេញពួកសេនាទាហ៊ានបារាំងសែស ដែលមានសះគុណជួយធ្វើរាជ្ការខ្មោចស្តេចអាពុក នោះពួកសេនាទាហ៊ានបារាំងសែស ជុំនួនៈ ១២ នាក់ ដែរចូលមកនៅ ៗ ធន់មិនបានស្លាប់អស់ សល់តែ ២ នាក់ ៗ ក៏ធន់មិនបាន ហើយនាំមប្រពន្ធយួន ហើយនិងកូនដែរកើតពីប្រពន្ធយួននោះត្រឡប់វិលទៅស្រុកបារាំងសែសវិញ

កាលក្រោយពួកបារាំងសែសចេញទៅនោះ ស្តេចយួនតាំងតែសង្កត់សង្កិនធ្វើបាបពួកលោកសង្ឃបារាំង ហើយនិងពួកយួនដែរចូលសាស្នាគ្រិះស្តាំង ហើយឲ្យចាប់បងក្រពើធ្វើបាប និងប្រហារជីវិតលោកសង្ឃបារាំងសែស ហើយនិងពួកចូលសាស្នានៅក្នុងស្រុកយួន ស្រុកតុងគីង ស្រុកកូសាំងស៊ីនជាច្រើន

ស្តេចនគរបារាំងសែស បានឮរ៉ាយវិញកទូរៀនជាច្រើនដងច្រើនគ្រា បុន្តែស្តេចយួនមិនទ៍ទូលស្តាប់ យកចិត្តទុកដាក់សោះ

បែះតែរិតធ្វើបាបពួកប្រជៅសាស្ត្រ ហើយនិងពួកបួលសាស្ត្រទៅ មិនបុន្តែម៉្លេះសោត ស្តេចប្អូនក៏នៅរឹងទទឹង មិនទទួលឲ្យជួប សំដៀងនិងរាជទូតនគរបារាំងសែស ហើយមិនព្រមទទួលមើល ស្លាប់ព្រះរាជសារ ដែរស្តេចនគរបារាំងសែស ឲ្យរាជទូតនាំ មកនោះផង

ឯស្តេចប្អូនឈ្មោះមិញម៉ាងនោះ ស្លាប់ប្រហែលក្នុងឆ្នាំ ដែរបួងម្ចាស់អង្គឌួងយើង បានឡើងសោយរាជសម្បត្តិគ្រប់គ្រង ក្រុងកម្ពុជាធិបតី ហើយនៅវេលាគ្រានោះគៀបែះតែក្រែងថាស្តេច ស្រុកបារាំងសែសរ និងបាត់កងទាត់ឲ្យមកផ្ចាញ់អស់ពួកយួន ដែរ វាពាព្រៀតបទអាក្រក់ខុសនិងធម៌ .

លុះដល់ស្តេចធៀវទ្រី បានឡើងសោយរាជក្នុងស្រុកយួន នោះឃើញអន់កុំណរាប និងពួកបួលសាស្ត្រគ្រិះស្តាំង ហើយអត់ គុំនុំឞតុំគួននិងពួកប្រជៅសាស្ត្រគ្រិះស្តាំង ហើយបានបើកពួក ប្រជៅសាស្ត្រ ដែលឡាចស្តេចអាពុកបាប់ដាក់គុកទាំងប៉ុន្មានៗ

នោះប្រគល់ខ្លួនឲ្យកុំមិខ្លាំង នាំយកកប៉ាល់ចម្បាំងបារាំងសែស ទាំងអស់ ប៉ុន្តែអំណាសត៍មកក្រោយទៀត ស្តេចជៀវទ្រីក៏តាំង ឲ្យធ្វើបាបសង្កត់សង្កិនទៀត ហើយបង្គាប់ឲ្យយកទោសដល់ជីវិត ផិតជុំនុំមជុំរះ ពួកបារាំងទាំងប៉ុន្មាន ដែលប្រទះឃើញនៅក្នុង ស្រុកយួន ឃើញស្តេចយួនពព្រិតបទ់ផិតសប្បុរស់ដូច្នោះ នោះ រាជ្ការក្រុងបារាំងសែសក៏យល់ជា និងធន់អត់ទ្រាំមឲ្យស្តេចយួន ពព្រិតដូច្នោះតែអង្វេងទៅទៀតមិនបាន លុះគិតស្រេចដូច្នោះ ក៏ចាត់កប៉ាលចំម្បាំង ២ មកបាញ់បន្តក់គ្រាប់បែកលើស្រុកទូរ៉ាន ផែះផ្ទះសំម្បែងនាក់ស្រុកទាំងប៉ុន្មានអស់ ឯនាក់ស្តេចជៀវទ្រី កើតទុក្ខអន់ចិត្តហើយភ្យែបារម្ភជាខ្លាំង ក៏អស់បុណ្យទ់ទួលអនិច្ចកម្ម ហើយមានកូនប្រុសនាមឈ្មោះទឺឌិគ ឡើងគ្រងរាជសម្បត្តិជា ជំណោរស្តេចរាពុក ក្នុងចុលស័ករាជ ១២០៩ ឆ្នាំមមែនព្វស័ក្ស នៅវេលានោះសេចក្តីដែរពព្រិតជាបឋមកម្ម គឺសង្កត់សង្កិន កុំហែងកុំហោកយាត្យពួកបារាំង ក៏រឹងរឹតតែខ្លាំងឡើងនិងគិតគន្ធា ពុំបានឡើយ

លុះដល់ ១០ ឆ្នាំ តមកទៀត នោះរាស្ត្រស្រុកបារាំងសែស ហើយនិងរាស្ត្រស្រុកអាំងគ្លេស និងជនអត់ទ្រាំមពុំបាន ក៏ចាត់កងទាព់ស្រុកទាំង ២ ជិះកប៉ាល់ភ្លើង មកធ្វើទោសផ្ដន្ទាអស់ពួកចិន្ត ដែរវាពព្រិតបទអធម្ម រូបយួនវាធ្វើបាប ហើយបែរតែប្រមាទមាក់ងាយពួកបារាំង ហើយនិងពួកបារាំងនាក់ដើរស្រម៉ុទ នោះកងទាព់នគរទាំង២ បូលលុកវាយស្រុកក្រុងស្ដេចក្រុងចិន្ត ប្រាប់ចិន្តទាំងអស់ទាំងនគរ ឲ្យដឹងខុសនិងត្រូវ

លុះបានធ្វើទោសផ្ដន្ទាស្រុកចិន្តរួចហើយ ពួកកងទាព់អាំងគ្លេស ក៏ត្រឡប់វិលទៅស្រុកវិញ នៅតែបារាំងសែស ដែរកាលមុននោះបានធ្វើទោសផ្ដន្ទាអស់ពួកយួន ក៏មកឈប់នៅស្រុកអាំងជូស៊ិន វាយយកស្រុកទូរ៉ាន់ ក្នុងឆ្នាំមមីសំរិទ្ធិស័ក្ក យកស្រុកព្រៃនគរក្នុងឆ្នាំមមែឯកស័ក្ក ហើយវាយយកបានអស់ទាំងស្រុកកូសាំងស៊ីនក្នុង ២ ឆ្នាំ ៣ ឆ្នាំ តមកក្រោយទៀតនេះ ព្រោះតែហេតុដូច្នេះ បានជាបារាំងសែសច្បាំង និងស្ដេចយួន

១ ទៀតហេតុដូចម្ដេច បានជាស្រុកខ្មែរយើង ក៏លែងភ្ញៀបារម្ភនិងយួន រួចហេតុដូចម្ដេចក៏បានជានៅតែស័ត្រូវ ១ បំណែកគឺស័ត្រូវនិងស្ដេចសៀម នោះគាល្មោះព្រះបាទសំម្ដេចព្រះនរោត្តមជាព្រះរាជបុត្រា ថ្លៃនៃព្រះបាទសំម្ដេចព្រះហរិរក្សរាមាឥស្សរាធិប្ដី (ព្រះអង្គឌួង) ដែរពាកភាស្ទ្រទាំងពួង ហៅថាហ្លួងសុរិណ្ណកោដ្ឋ បានឡើងស្នោយរាជសម្បត្តិ គ្រងក្រុងកម្ពុជាខ្មែរយើង ក្នុងបុលស័ករាជ ១២២០ ឆ្នាំមមែឯកស័ក្ក នោះទ្រង់មានព្រះរាជ—ហារទ្វេបារម្ភក្រែងតែស្រុកបារាំងសែស មិនមកជួយទំនុកបំរុងក្រុងកម្ពុជា នោះស្ដេចសៀមនិងសង្កត់យកក្រុងកម្ពុជា រួបពីនោះមកទៀតនៅមានព្រះអង្គម្ចាស់ស៊ីវត្ថា ដែរជាព្រះរាជបុត្រាទី ៣ នៃព្រះបាទសំម្ដេចហរិរក្សរាមា ដែរមិនគួរគាប្បីយនិងត្រូវឡើងគ្រងរាជសម្បត្តិ ដិណាងអង្គសំម្ដេចព្រះវររាជបីតា នោះគិតបាស់បោះតាំងជាកងទាព់ ហើយរត់ទៅជ្រកក្នុងស្រុកសៀម

ឯស្ដេចស្រុកសៀមប្រាប់ឲ្យតែម្ចាស់ស៊ីវត្ថា លើកកងទាព់ចូលមកច្បាំង និងព្រះបាទសំម្ដេចព្រះនរោត្តម ក្នុងក្រុងកម្ពុជាវិញ

ដូចកាលដែរព្រះរាជវង្សាខ្មែរទាំងបុរាណ ដែរក្បត់តាំងតែអំពីដើម រៀងមក នោះតែរត់ទៅជ្រកពឹងបុរីសៀម ៗ តែងតែជួយកាន់ជើងរៀងរៀបដរាបមក

នោះនៅវេលានោះ ក្នុងស្រុកខ្មែរក៏តាំងមានសឹកសង្គ្រាម ប្បារាំងរាំងដល់ឡើងវិញ មិនតែប្បាំងពីព្រោះព្រះអង្គស៊ីវត្ថានោះឡើយ នៅមានពួកក្បត់តាំងខ្លួនជាអាចារ្យ អាក្បត់ ១ នោះ ឈ្មោះអាស្វា វាបំបាស់ខាងខែត្រ ទ្រាំង បន្ទាយមាស ពាម ហើយលើកកងទាត់ លុកវាយកស្រុកកំពត អា ១ ទៀត ឈ្មោះពោកំបោរ វាបំបាស់ខាងខែត្រ ក្រចេះ ធ្លង ត្បូងឃ្មុំ បាភ្នំ

ឯអាក្បត់ទាំងពីនាក់នោះ កាលកងទាត់ហ្លួងដេញប្រកិតជិតនឹងចាប់បានខ្លួនវា ៗ រត់ទៅ ចូលក្នុងដែនស្រុកកូសាំងស៊ីន ពួនក្នុងស្រុកពាមមាត់ជ្រូកលង់ហោរ ដែរនៅក្នុងអំណាចយួន ៗ វាទំនុកបំរុងអាក្បត់ទាំងពីនោះ ព្រោះយួនវាជាមហាសត្រូវនឹងខ្មែរយើងពីដើមមក ស្រេចហើយអាក្បត់ទាំងពីនោះវាត្រឡប់ចូលមកដើររាតត្បាត បំបាស់បំបោរអស់រាស្ត្រប្រជា ក្នុងស្រុកខ្មែរទៀត

នៅរដូវដើមឆ្នាំ  ចុលសករាជ ១២២២  ឆ្នាំវិកទោស័ក្យ ចៅហ្វាយស្រុកបារាំងសែស  នៅស្រុកព្រៃនគរ  ដែរបង្គាប់លើកងទាព ជើងគោក ជើងទឹកទាំងបុន្មាន ឲ្យនាម៉ឺនបារាំងសែស ១ នាក់  ជិះកប៉ាល់មកបតនៅខែត្រកំពត  ស្រេប់ឡើងទៅថ្វាយបង្គំមគាល់ ព្រះបាទសម្ដេចព្រះនរោត្តម  កាលទ្រង់គង់នៅព្រះ-បរមរាជវាំងឧដុងមានជ័យ ហើយយកសេចក្ដីក្រាបបង្គំទូល តាមផ្លូវរាជ្ការ  ថារាជ្ការបារាំងសែសគិតសំរេចថា  ត្រូវយកស្រុកកូសាំងស៊ីន ទុកជារបស់រាជ្ការបារាំងសែស  ព្រះបាទសម្ដេចព្រះ-នរោត្តម បានទ្រង់ជ្រាបដូច្នោះ ក៏មានព្រះរាជហឫទ័យសោមនស្សនិងរាជ្ការបារាំងសែស  យកស្រុកកូសាំងស៊ីន  ផ្គាប់ជារបស់បារាំងសែស លុះនិលងបាន ១ ខែតមក នោះព្រះបាទសម្ដេចព្រះ-នរោត្តម ទ្រង់តែងរាជទូតឲ្យទៅជួយអំណរ ចៅហ្វាយស្រុកបារាំងសែស នៅស្រុកព្រៃនគរ ឯស្មៀមកាលឃើញ ព្រះបាទសម្ដេចព្រះនរោត្តម  ព្រមទទួលស្រុះស្រួលនិងបារាំងសែស ក៏អន់ចិត្ត

ដ្បិតបារាំងសែស ខ្លាំងពូកែជាងខ្លួន ហើយបានមកទំនុកបំរុងក្រុងកម្ពុជា ស្រេចហើយធ្វើសំបុត្រសន្យា បន់បយយួន ហើយនិងសៀម ពីស្រុកខ្មែរ ដាក់ស្រុកខ្មែរឲ្យនៅក្នុងទំនុកបំរុង រាជ្ការបារាំងសែសដែរជាមហានគរធំវិញ ហើយហាមប្រាមនគរសៀម នគរយួន កុំឲ្យលើកទាព់មកជន្លើម យកក្រុងកម្ពុជាតទៅ

តាំងពីបានរាជ្ការបារាំងសែស មកទំនុកបំរុងកាលណ៎ា ក្រុងកម្ពុជាក៏បានសំបូណ៌សោភីនី ឥតមានស័ត្រូវឯណាមកបៀតបៀនយាយី ហើយអាណាប្រជានុរាស្ត្រក៏រកស៊ីសុក្ខសាប្បាយ តាមជោរសុចរិតពិត្យត្រង់ ពុំមានព្រួយថើយភិតភ័យរត់លួន និងសឹកសាមសង្គ្រាមដែរទៀតឡើយ

កាលណ្ណោះបារាំងសែស បានធ្វើរាជ្ការថ្វាយសម្ដេចព្រះនរោត្តម ជួយច្បាំងដេញចាប់អាចារិយ៍ស្វា ពោកុំបោរ ឯខ្លួនពោកុំបោរបាក់ទាព់ពីក្នុងខែត្របាភ្នំ រត់ទៅដល់ស្រុកកំពង់ធំម- ខែត្រកំពង់ស្វាយ ចាប់បានខ្លួនហើយប្រហារជីវិតនៅទីនោះ

នៅវេលានោះក្នុងទន្លេសាប ទន្លេធំ ហើយនិងតាមដងស្ទឹង មានតែទូកថ្ងៃបិន្ត ទូក ២ ទូក ៣ ឯស្រូវថ្លៃ ៣ ហ៊ឹង ៥ កាក់ ដឹកដាក់ដល់ជើងកំពង់ បើទិញដល់ផ្ទះថ្លៃតែ ៣ ហ៊ឹង ២ កាក់កន្លះ ដ្បិតផ្ទះឆ្ងាយពីជើងកំពង់ ពីបាកដឹកនាំមតាមផ្លូវទេះដែរមិនទាន់មានថ្នល់

ឯសំពត់ជាឱបទេសឯកថ្លៃអស់យ៉ាង រកនិងទិញប្រើការពុំបានទេ ហើយវេលាគ្រានោះ សុតតែចិន្តវារកស៊ីក្នុងស្រុកខ្មែរ យើងនេះបានបំណោញច្រើនណាស់ ហើយប្រាក់ក្នុងស្រុកខ្មែរទាំងប៉ុន្មាននៅដៃវាទាំងអស់ ហើយកាលណ្ណាវារកស៊ី បានប្រាក់ច្រើន វានាំមយកទៅស្រុកចិន្ត

ឯក្លូប៉ាល់ភ្លើង ដែរមកដល់ក្នុងស្រុកខ្មែរមុនគេ នោះជាក្លូប៉ាល់បារាំងសែស ខ្ញុំបានឃើញជាក់និងភ្នែក ហើយនៅចាំមច្បាស់ដល់ឥឡូវ កាលក្លូប៉ាល់នោះមកដល់កំពង់ល្វង់ នាក់ស្រុកផ្អើលគោឡោ ដ្បិតធ្លាប់ថាក្លូប៉ាល់ ឥតញ្ចោង ប៉ៃវ ក្រដឹង

ហើយបើកភ្លើងលើទឹកបាន មនុស្សប្រុសស្រីចាស់ក្មេង រត់ទៅមើលលាន់ ប្រពួនប្រពាន់លើគ្នា ហើយឆ្ងល់មិនយល់ថាដូចម្តេចសោះ ស្រាប់តែឃើញរលកបែកពុះខាងក្បែរ ហើយភ្លើងពោរទឹកពីក្បាលជាះទៅចំហៀងសង្ខាង កើតជារលកបោកទៅខាងមាត់ច្រាំង នាក់ដែរមកមើលទាំងបុគ្គាន នោះអស្ចារ្យលាន់មាត់ស្រែកហែយ៉ោហែយ៉ា អឺកក្រធិកគឹកកងរំពង មើលមិនដាក់ភ្នែកដោយសារឃើញ ផ្សែងចេញតាមបំពង់ភ្លើង ហើយឮសន្ធឹកគ័គុកគ័គាក់ ពីខាងក្នុងក្ប៉ាល់នោះ ទាំងហ្លួងក៏ស្តេចមកជាមួយនិងនាម៉ឺនមុក្ខមន្ត្រី ហើយទ្រង់យាងទតមកពីមាត់កំពង់មកជាច្រើនម៉ោង ទ្រង់ព្រះសន្ធិះសង្ស័យនិងក្ប៉ាល់ ព្រោះមិនទាន់ជ្រាបថាធ្វើដូចម្តេចខ្លះ អស់ទាំងនាក់ចាស់ប្រជាឈប់ឈរមើលរំពឹងគិត ហើយយល់ថានេះជាមនុស្ស នាក់ស្រុកគេរធំម គៀមកដល់ស្រុកយើងហើយៗ មកជួយទំនុកបំរុងយើងស្រុកយើងនិងបានចំរើន ផ្លូវវីធីជាថ្មីឡើងទៀត ប្រហែលជានិងត្រឡប់បានឡើងជានគរធំមដូចខ្មែរដើមវិញ នោះហាប៉ុដើម

តាំងពីព្រះបាទសម្តេច ព្រះនរោត្តម សោយរាជ្យរៀងមកដល់
ឥឡូវនេះ នោះក្នុងស្រុកខ្មែរ វិធីខាងបំណែរផ្ចាក់បំរើនហើយថ្កើង
រុងរឿងជាងអំពីដើមនោះច្រើនណាស់ ហើយគ្មានសត្រូវមកបៀត
បៀន ពីព្រោះមានអ្នកមានបុណ្យអំណាច ដែរទំនុកបំរុងយើង
គេគ្រប់គ្រងពួកយួន នៅស្រុកកូសាំងស៊ីន ហើយសៀមក៏ខ្លប
មិនហានមកបៀតបៀនទៀត តាំងពីវេលាគ្រានោះរៀងមក

ចូលអស់លោកអ្នកទាំងឡាយ នាម៉ឺនក្តីរាស្ត្រក្តី មើលហើយ
ពីបារណាគិតឲ្យសព្វទៅឃើញឬទេ ស្រុកយើងសព្វថ្ងៃនេះ
ខុសគ្នានឹងកាល ៥០ ឆ្នាំមុន នោះឃើញខុសគ្នាដូចម្តេចខ្លះ
ហើយគិតកាលដែរស្រុកកើតចំបាំងរាំងជល់ ហើយស្រុកឥឡូវដែរ
បាននិងសុក្ខសាប្បាយខ្សែមខ្សាន្តគ្រប់ទីកន្លែង ហើយប្រាក់ក៏មាន
សម្បូរណ៍ក្នុងស្រុកខ្មែរយើង គ្រប់ផ្ទះសម្បែងក៏មិនដែលដាច់ ខ្លះ
បាសោះ! គង់តែងមានប្រាក់បាខ្លះរាល់ផ្ទះគ្រប់គ្នា ហេតុដែរ
បានសម្បូរណ៍ទាំងនេះពីព្រោះត្បិ នោះឃើញជាសេចក្តីអត់ឃ្លាន
មិនសូវមាន តាំងតែពីកាលបារាំងសែស ចូលមកនៅក្នុងស្រុក
យើង ហើយស្រុកយើងក៏មិនយូរទៀយ សម្បូរណ៍មានធន់ធាន
ធើដូចជាខ្លួនតានេះអាយុស្ម ៨០ ឆ្នាំញ៉ាំហើយៗ ចាំមដំណើររឿង
ព្រេង នាំមកនិទានឲ្យកូនចៅទូតល្អតលាសៅឯក្រោយ ឲ្យដឹង
រឿងបារាំងសែសនេះ- កាលពីមុនដូចម្តេច ក៏មកទៀតដូចម្តេច
មួយទៀតយើងសព្វថ្ងៃនេះ ចូរចាំមកុំភ្លេចសេចក្តី ដែរមនុស្ស
ពីដើមធន់រងលំបាក ទុក្ខវេទនានោះដូចម្តេចខ្លះ ហើយកុំភ្លេច
គុណបារាំងសែស តែនាំមមាត្មអាក្រក់គិតការទុច្ចរិតស្ងាត់កុំបាំង
ហើយ នោះវានាំមឲ្យស្រុកនគរយើង ត្រឡប់ទៅកន្លែងដើមវិញ
ដូចកាលគ្រាដែរបែះតែកើតច្បាំង កុំសទ់អត់ឃ្លាន ២០ ឆ្នាំម្តង
១០ ឆ្នាំម្តង ដូនណាឃើញទាត់យួនមក ដូនណាឃើញទាត់
សៀមមក ម្តងទាត់មកពីស្រុកនេះ ម្តងទាត់មកពីស្រុកនោះ ហើយ
មានទាំងពួកចោរកុំណាចកាចផ្តុំមគ្នា លើកជាពួកជាកង លួច
ប្លន់កាប់ចាក់សម្លាប់គ្នា ហើយដុតផ្ទះសម្បែងវត្តអារាមវិនាសអស់

អើកាលណោះប្រហែល ៥០ ឆ្នាំមកហើយ នោះស្រុកយើងនោះគ្មានអ្វីសោះ សៀមហើយនិងយួនវាមកឈ្លៀតសង្កត់សង្កិនយើង ហៀប ៗ តែនិងស្រូនឈ្មោះផង ដល់មកឥឡូវនេះមានគេស្គាល់យើងទាំងពីភព ហើយសារពើផលជំនួញយើង គឺស្រូវ ក្របាស ម្រេច ហើយនិងត្រីពីក្នុងទន្លេព្រែកបឹងស្ទឹងយើង ដែរកាលពីដើម មិនសូវបាននាំចេញទៅប្រទេសក្រៅ ហើយច្រើនតែឈ្មួញចិនចូលទិញ នោះឥឡូវនេះមានកប៉ាល់ភ្លើង នាំទៅដល់ស្រុកម៉ីល ស្រុកចិន ស្រុកយីពុន ស្រុកយ៉ាវ៉ា ហើយនិងប្រទេសយូរ៉ុប

កាលដើមឡើយគេមិនស្គាល់ស្រុកយើង ឥឡូវគេមកពីគ្រប់ទិសដីបន់ មកមើលក្រុងភ្នំពេញ នគរធំ នគរវត្ត ហើយបើបង់ទិញទំនិញអ្វី ៗ មានគ្រប់ ប្រទេសក្រោមមេឃនេះ ក៏មានឲ្យទិញទាំងអស់ក្នុងស្រុកខ្មែរ កប៉ាល់សាលុប័របស់ចិន្តភ្លឹង ឬរបស់បារាំងសែសខ្លះមានសព្វថ្ងៃនេះជាង ៦០ បើកជួញជួលជិះសំពៅងទូក នៅមកព្សារហែរតាមទន្លេ បើទៅពីភ្នំពេញទៅព្រែកនគរបំម៉្យពៃ ២៤ ម៉ោង ឯស្រុកព្រែកនគរនោះ កាលដែរនៅក្នុងដៃយួន វាធ្វើជាម្ចាស់ស្រុកនោះ យើងមិនបានទៅសោះ

បើទៅពីភ្នំពេញទៅបាត់ដំបង ទៅក្របៃ បំម៉្យផ្លូវតែ ១២ ម៉ោងដល់ ដែរកាលពីដើមបំម៉្យផ្លូវតែ ៨ ថ្ងៃ បើទៅតាមផ្លូវទន្លេធំ ទៅស្រុកលាវស្រុកខោង បំម៉្យផ្លូវសព្វថ្ងៃតែ ២៤ ម៉ោង ហើយបើឡើងស្រុកលួងប្របាង បំម៉្យផ្លូវមិនដល់ ២០ ថ្ងៃទេ បើទៅតាមផ្លូវស្រម៉ុទ ពីព្រែកនគរទៅស្រុកបាងកកតែ ៤ ថ្ងៃ បើទៅសីង្គះបួរតែ ២ ថ្ងៃ ឯស្រុកលង្កា ដែរយើងស្គាល់ឈ្មោះ ដោយសារតែគម្ពីរព្រះបាឡី នោះយើងមិនដែលទៅសោះ កាលពីដើមដ្បិតស្រុកឆ្ងាយណាស់ សព្វថ្ងៃនេះទៅតែ ៨ ថ្ងៃដល់ ឯស្រុកបារាំងសែសបំម៉្យផ្លូវតែ ២២ ថ្ងៃ ស្រុកខ្មែរយើងសព្វថ្ងៃនេះមិនមែនជាស្រុកដែលឥតគេណាស្គាល់ នាក់នគរទាំងពីភពគេក៏មិនសល់និងស្គាល់យើង ហើយនគរណាដែរយើងមិន

ស្គាល់មិនដែលឮនិយាយសោះ ឥឡូវនេះយើងស្គាល់ទាំងអស់ ហ្លួងយើងក៏បានស្ដេចទៅស្រុកបារាំងសែស ហើយបានចូលទតស្រុកសឹង្ហលលង្កា និងព្រែកជិកធំ ដែរឲ្យបារាំងសែសជិកទំលុះពីសមុទ្រទិសឯកើតកាត់ទៅសមុទ្រទិសឯលិច ព្រែកជិកនោះជាផ្លូវសមុទ្រធំ ក្នុង ១ ឆ្នាំមានកប៉ាល់ភ្លើងជាច្រើនពាន់បើកចេញចូលទៅមកមិនដែលដាច់ អស់ទាំងលោកសេនាបុត្តិព្រះអង្គម្ចាស់ខ្សត្រី និងចៅជិតចៅចមអស់អ្នកក្នុងវាំង ក៏បានទៅឃើញស្គាល់ស្រុកបារាំង ឃើញក្រុងប៉ារិស ជាទីជ្យជុំនុំមស្រុកបារាំងសែស ឯក្រុងប៉ារិសនោះជាក្រុងធំ និងគិតគន្ធាត្រារាប់ពុំបាន បើរាប់តែរាស្ត្រចំណុះស្រុក ក្នុងទីជ្យជុំនុំមក្រុងប៉ារិសនោះ ប្រហែលជំនួនមនុស្ស ២ នគរស្រុកខ្មែរយើង ទើបប្រហែលនិងមនុស្សក្នុងទីជ្យជុំនុំមក្នុងប៉ារិស ១ ហើយ ១ ទៀតកូនខ្មែរយើង ក៏បានទៅរៀនអក្សរបំណែណាវិជ្ជា នៅស្រុកបារាំងសែស ហើយ ៗ ត្រឡប់មកវិញ ឡើងជាមនុស្សចេះដឹង នាំមកដំណឹងរឿងរ៉ាវពីស្រុកបារាំងសែសយកមកនិយាយមុខគួរឲ្យស្ដាប់ ដ្បិត

ស្រុកនោះជាស្រុកកាលមុន ៥០ ឆ្នាំ ខ្លួនខ្ញុំ អាពុកម្ដាយ ជីតាជីដូន ជីទួតលួតលាយើង មិនដែលឮឈ្មោះសោះ អើនេះគឺបារាំងសែស គេបើកលោកបំភ្លឺឲ្យយើង បើគ្មានបារាំងសែស ម្ល៉េះសឹម យើងមិនដឹងការអ្វីជាច្រើនទេ គ្រាន់តែឃើញថាមនុស្សស៍ ឃើញតែស្រុក ហើយឃើញតែបំណែះរីដ្ឋាយ៉ាងខ្ពស់បុណ្ណឹង ឯឥឡូវនេះ យើងដឹងស្គាល់ថាបារាំងសែសនេះ ជាអ្នកមានរិទ្ធីអនុភាព មានប្រាជ្ញាឆ្លាតច្រើន ហើយការប្រើរបស់អ្វីៗ តែនិងគ្រឿងម៉ាស៊ីន គ្រឿងច័ក្រ ឃើញរិតតែពូកែឡើងទៀត, ជិត ៗ តែនិងមានរិទ្ធីបែស្ដា ដូចទេវតា

គេយកទឹកជាច្រើនមកដាក់ក្នុងឆ្នាំងធំ ដុតភ្លើងដាំឲ្យពុះ ៗ ជាខ្លាំង កុំឡាំងទឹកពុះនោះស្ទុះពីក្នុងឆ្នាំង ដាក់វិលកង់ដែរនៅលើផ្លូវដែក ឬដាក់ភ្លៅច័ក្រ វិលស្លាបច័ក្រក្នុងទឹក នៅខាងកន្សៃកប៉ាល់ អំណាចកុំឡាំងទឹកពុះនោះ គេយកប្រើឲ្យវិលកង់រទេះបើកលឿនឯង មិនបាច់ពឹងកុំឡាំងសេះ ឬសត្វពាហនះណាៗទៀត ឲ្យអូសទង់ទាញឡើយ ឯកប៉ាល់ក៏បើកលឿនក្នុងទន្លេសមុទ្រ ដោយសារអំណាចទឹកពុះនោះដូចគ្នា មិនបាច់ប្រើក្ដោងបែរក្រដឹងឡើយ

ពួកកូនខ្មែរយើង ដែរបានទៅស្រុកបារាំងសែស ហើយត្រឡប់មកវិញនិយាយថាបារាំងសែស ចេះយកធ្យូងថ្មរមកដុត ហើយបង្ហូតភ្លើងតាមបំពង់ទៅគ្រប់ផ្ទះសំម្បែង ឯភ្លើងដែរចេញពីបំពង់បង្ហូតនោះ ភ្លឺហ៍ដូចភ្លើងចង្កៀងប្រេងកាត ក្នុងស្រុកខ្មែរយើងនេះ កាលដើមអុចបន្លុះ ប្រេងដែះទៀនក្រមួន ឥឡូវនេះ រាល់ផ្ទះអុចចង្កៀងប្រេងកាត ឯប្រេងកាតនោះ ជាប្រេងអន្លូងកើតពីក្នុងដី នៅប្រទេសឆ្ងាយណាស់ ដែរកប៉ាល់បារាំងនាំយកមកលក់ក្នុងស្រុកខ្មែរ ។ ឯចង្កៀងទាំង ៨០០ ដែរបំភ្លឺហ៍ ក្រុងភ្នំពេញសព្វថ្ងៃនេះ មិនមែនជាភ្លើងដែរដុតធ្យូងថ្ម បង្ហូតតាមបំពង់ទេ ភ្លើងនេះជាភ្លើងអគ្គិសនី មានបន្លឺហ៍ដូចផ្លេកបន្ទោល កណ្ដាលអាកាស ដែរបារាំងគេចេះផ្សំធាតុ យកកុំហាប់ធ្វើឲ្យរត់តាមខ្សែលួស

អើកាល ៩០ ឆ្នាំមុននេះ យើងមិនទាន់ដឹងជាបារាំងគេ មានខ្សែលួសរៃទៅមករកគ្នា ហើយស្តាប់គ្នាបានពីចំងាយ ឥឡូវ យើងឃើញថាគេស្រាយគ្នា ពីស្រុកវៀងច័ន្ទ មកភ្នំពេញ ពីភ្នំពេញទៅល្ហងប្របាង ពីព្រៃនគរទៅហាន់ណោយ ទៅស្រុក ហ្វេ ទៅបាងកក ទៅស្រុកចិន្ត ហើយទៅដល់ស្រុកបារាំងសែស ផង តែក្នុងពីបីមីនុតស្តាប់ដំណឹងដឹងការទៅវិញទៅមក ដំណឹង ដើររត់តាមខ្សែលួសនោះ រហ័សណាស់ស្មើនិងជីវិតដើរគិត អើ បើគិតសព្វគ្រប់ទៅ ឃើញថាបារាំងគេមានគុណនិងយើង មិន តែប៉ុណ្ណោះនៅមានគុណច្រើនជុំពូកទៀត បារាំងសែសនេះគេ មានប្រាជ្ញាឆ្លាតគ្មានទុញទាល់សល់និងអ្វីសោះ គេនាំមកយក នៅរបស់ដ៏ប្រសើរថ្មីមកបង្ហាញបំភ្លឺប៉ាយើង

១ ទៀតគេនាំមកម៉ាស៊ីនហិបច្រៀង បិតសំឡេងភាសាដូច មនុស្សច្រៀងនិយាយគ្នាមែនទែន តាមតែទំនើងបិត្រង់ណាប៉ង់ ស្តាប់ចុះ ហើយមានកុនស្រមោលផ្ទុះរូប រីស្បៀងដូចឃើញស្រុក

បារាំងសែស ផ្ទុរីញ្ញមនុស្សម្នាដើរទៅមកដូចរូបរស់ ដែរគេឃើញក្នុងស្រុកបារាំងសែសក្រុងប៉ារីសដូចម្ដេច នោះយើងនៅតែស្រុកខ្មែរ ឃើញវិស្សដូចយើងបានឃើញស្រុកបារាំងសែសខ្លួនយើង

គេបែះធ្វើគ្រឿងថតរូប បើថ្លូលតែពីបីរៀល បានរូបរបស់ខ្លួនយកមករក្សាទុក ហើយជាប្រយោជន៍បានរក្សារូបអាពុកម្ដាយទុកតទៅមុខ ឲ្យកូនដឹងស្គាល់ជារូបជីតាជីដូន ដែរស្លាប់ជាអង្វែងរាប់រយឆ្នាំមកហើយនោះ

គេនិយាយថាបារាំងសែស សព្វថ្ងៃនេះបែះហោះលើអាកាស ដោយអំណាចយន្តគោមហោះៗលឿន ដូចសត្វហើរពាក្យនេះពិតមែន បើមិនជឿសួរមើលបុះអែះ ថាបើបារាំងទាល់បំណែះហើយតទៅមិនយកយន្តហោះនោះមកឲ្យយើងឃើញទៀត

ព្រះបាទសម្ដេច ព្រះនរោត្តមជាអម្ចាស់ផែន្ទី នគរយើងព្រះអង្គបានផ្ញើរផ្ការផែន្ទីទាំងបុន្មាន ឲ្យបារាំងសែសគ្រប់គ្រងតាងព្រះនេត្រ ព្រះឱស្ឋជាមួយនិងសេនាបុត្តី ចៅហ្វាយស្រុក

បាឡាត់សុភាយោក្យាត់ ហើយនិងពួកនាក់រាជ្ការខ្មែរជាច្រើនពាន់ ដែរធ្វើរាជ្ការ នៅក្នុងបង្គាប់រេសីដង់បារាំងសែស ឯប្រាក់ទាំង ប៉ុន្មាន ដែរបានមកពីពន្ធគ្រប់ជុំពួក និងប្រាក់ដែរលោះថ្លៃធ្វើ រាជ្ការនោះយកមកចាយ ប្រើការជាប្រយោជន៍ បំរើនព្រះរាជ កាឆីទាំងអស់ បានប្រាក់នោះដែរយកចាយ រៀបចំមតែងក្រុង ភ្នំពេញដែរសព្វថ្ងៃនេះ បានកើតឡើងជាក្រុងល្អរុង្គុមរុង្គើង ដែរ ពួកខ្មែរទាំងប៉ុន្មាននៅខេត្រក្រៅ តែងតែងចូលមកមើល ឥឡាយ សរសើរគ្រប់គ្នា ហើយនាក់ប្រទេសក្រៅក៏មានចូលមកមើលលេង នៅក្រុងភ្នំពេញជាច្រើន ក្រៅពីរៀបចំមតែងក្រុងភ្នំពេញ នោះរាជ្ការនៅរៀបចំមតែងដ្យ ទីជុំនុំមរូមខេត្រជាប់អន្លើហ៍ទៀត

ហើយធ្វើប្ញ៉ុល់ធ្វើស្ពានផ្លូវ ឲ្យរទេះប័រទោមកងាយស្រួល ហើយ នៅគិតនឹងធ្វើផ្លូវថ្នល់ ឲ្យគ្រប់ទីដីបង់ក្នុងស្រុកខ្មែរ ឲ្យបាន់ជិក តាមជុំនួញទំនិញកាត់ទៅលក់ ក្នុងភូមធំម ៗ ងាយងាយ ហើយបាន ឆាប់ក៏ឆាប់ ឯសោហ៊ុយដឹកនាំមទំនិញទៅឯផ្សារធំមក៏ហោក

១ ទៀតគ្រឿងឥឡូវយបាគិតធ្វើរទេះភ្លើង ក្នុងរទេះ ១ ទាញ យោងបានរទេះ ១០ កាត់ផ្ទុកទំនិញ ហើយនិងនាក់ដំណើរ ពី បាត់ដំបងមកស្រុកភ្នំពេញទៅព្រៃនគរ គ្រឿងឥឡូវយគិតបានិង ធ្វើផ្លូវរទេះភ្លើង ១ ទៀតកាត់ទៅលាវទៅយួន ហើយនិងស្រុកសៀម ប៉ុន្តែផ្លូវរទេះប័រឋភ្លើងនោះ និងធ្វើឲ្យទាន់ឆាប់ភ្លាមនោះមិនបានទេ ប៉ុន្តែគ្រឿងបានិងធ្វើឲ្យបាន ,ហើយក្នុងរវាងមុន ២៥ ឆ្នាំនេះ នោះ ស្រុកខ្មែរនិងមានផ្លូវរឋភ្លើងប័រទោមកជាប់គ្នា និងនគរដែរនៅ ជុំមវិញយើង ឯផ្លូវទៅស្រុកយួរ៉ុបស្រុកចិន្តស្រុកយីពុន នោះ មានផ្លូវក្ប៉ាល់ភ្លើងក្ប៉ាល់ជុំនួញស្រាប់ហើយ កាលណាមានផ្លូវគ្រប់ បរិបូណ៌នោះស្រុកខ្មែរយើង ក៏នឹងត្រឡប់ឡើងជាទីប្រជុំមផ្លូវ ជុំនួញធំម ១ , ហើយនគរក៏និងបានជាធំមរុង្គុមរុង្គើងឡើង សំគួរ តាមលំដាប់ស្រុកបូរាណខ្មែរដើមវិញ ពួជអំបូរកូនចៅខ្មែរ ដែរ ជំណារត៍វង្សត្រកូល មិនបង់កុំណើតជាត៍ ងាយសារក្រឡាប់ ឡើងបានជាពួជនាក់នគរធំមនិងគ្រឿងវិញ

រីឯទាត់ទឹងចំម្បាៈបារាំងផល់ យើងក៏អស់មានអំពល់ សេចក្ដី ភ្សៃបារម្ភ ដ្បិទបារាំងសែស គ្យេគិតតែបង្រៀនប្រដៅបំណែះ វិជ្ជាការ ឲ្យយើងរូបខ្លួនជាខ្មែរឆាក់ជា ហើ្យខ្លាំងពូកែ គ្យេៈរង់ សាលាបង្រៀនអក្សរបារាំងគ្រប់ទីកន្លែង ហើ្យគ្យេទំនុកបំរុងវត្តអារ៉ា ដែរបៈង្រៀនអក្សរស្ត្រាបាឡីខ្មែរ ហើ្យគ្យេចែករង្វាន់ឲ្យកូនសិស្ស ណាដែរខំរៀន ហើ្យគ្យេសុំតែគ្រប់គ្រងយើង ជាមួយនិង នាម៉ឺនខ្មែរណា ដែរមានចិត្តស្លូតត្រង់ ហើ្យរើ្សយកខ្លួនឲ្យធ្វើជា នាម៉ឺនឲ្យបានចំរើនក្នុងនគរ ហើ្យឲ្យយើងរាស្ត្រខ្មែរទាំងប៉ុន្មាន បានចំរើនសេចក្ដីសុខគ្រប់គ្នា ឯខ្លួនតានេះចាស់ហើ្យ គិតរំពឹង ច្រើនៗទៅ ឃើញទៅដល់របស់ដែរខ្លួន បានឃើញកាល នៅក្មេង គិតទៅដល់របស់ ដែរបានឃើញកាលខ្លួនធំហើ្យៗ គិតមកដល់របស់ដែរភ្នែកខ្លួនឃើញសព្វថ្ងៃនេះ គិតឃើញម្ដង ទៅ មុខគួរឲ្យកោតខ្លាចបារាំងសែសនេះណាស់ មកកោតនិង មានចិត្តសង្វាតឧស្សាហ៍ប្រាជ្ញាឆ្លាត ឯខ្មែរយើងឃើញខ្ជិល ច្រអូស ក្នុងខ្លួន ក្នុងចិត្តបន្តិច ឯបារាំងសែសចូលកូនចៅមើល

គ្យេបុះឃើញទេ តាំងពីប្រមាណ ១៥ ឆ្នាំរៀងមក ដែរគ្យេស្ដី រាជ្ការគ្រប់គ្រងស្រុកយើង ដែរមកដល់សព្វថ្ងៃនេះ គ្យេធ្វើបាន សេចក្ដីរូតរះ ហើ្យគំនិតគ្យេល្អ គ្យេគិតតែឲ្យយើងចំរើនបាន សេចក្ដីសុខ ឲ្យយើងចំរើនមានទ្រព្យសម្បត្តិ ហើ្យនិង រៀបចំមទីដី្យស្រុកយើងឲ្យរបបរៀបរយ តាមដោ្យវគ ដោ្យស្មើរ ហើ្យគ្យេបំបាត់មិនឲ្យមានខ្ញុំកញ្ញះ នាក់ងារអង្គ្រាក់ត្រមាក់ជៀវគុន គ្យេចែកដី្យឲ្យយើងរាល់គ្នា ធ្វើស្រែចំការរកស៊ី សព្វថ្ងៃនេះ ដី្យ របស់នណា នាក់និងធ្វើជាម្ចាស់ដី្យ ហើ្យផលស្រែចំការ ច្បារដំណាំម យើងក៏លក់បានថ្លៃ ជាងពីដើម

១ ទៀតមុខឲ្យសរសើរបារាំងនេះ ចិត្តគ្យេត្យក៏ជា និង នាក់កុំសទ់ទូរគត់ នាក់មានជំងឺហ៍ណោគាព្យាធិម្ល៉េះៗ គ្យេចាត់ គ្រូពេទ្យដាក់ឲ្យនៅគ្រប់ទីរេស៊ីដង់ស្រួមខេត្រ ឲ្យចាំមបីបាប់រាក្សា មើលថៃទាំមនាក់ជុំងឺហ៍ទាំងនោះ ក៏ឃើញជាចិត្តគ្យេល្អមែន ហើ្យ ឯយើងខ្មែរដែរនិងដឹងគុណាគ្យេនោះ គឺយកចិត្តឈើផ្កាល

ឲ្យគេតាមគំនិតដែរគេគិតធ្វើការអ្វី ៗ ឯសេចក្តីដែរឈឺឆ្អាល ឲ្យការគេនោះ ទុកប្រៀបដូចជាយើងស្រឡាញ់ស្រុកយើង ធ្វើរាជការតបស្នងសងគុណនគរយើង

កាលដែរបារាំងសែសទើបមកដល់នោះ នគរយើងកាន្តែតូចណាស់ទៅហើយ នៅតែពីត្រឹមខេត្តពោធិ៍សាត់ ទៅទល់និងព្រែកជីកខេត្តតាម ដែរភាសាយួនវាឲ្យឈ្មោះហៅព្រែកវិញតេ នៅសល់ពីត្រឹមខេត្តសំបូរណ៍ ទៅទល់និងខេត្តរំដួល ហើយនិងស្រុកត្បូងស្មៀង ទៅទល់និងមាត់ស្រម៉ុទខាងកើត ហើយខាតទាំងខេត្តកោះកុង ដែរបានទៅសៀម នោះមិនដឹងជាដំណើរដូចម្តេច ក៏បានជាកាន្តែតូចទៅដូច្នោះ ឯសព្វថ្ងៃនេះស្រុកយើងខ្មែរត្រឡប់បានឡើងជាធំវិញ កាលដែរបារាំងសែសទើបមកដល់នោះ មិនបានធំប៉ុណ្ណឹងទេ សព្វថ្ងៃនេះបានធំពាក់កណ្តាលថែមទៀត

កាលក្នុងរាជ្យ ព្រះបាទសម្តេច ព្រះហរិរក្សរាមា (ព្រះអង្គឌួង) ឬកាលក្នុងរាជ្យ ព្រះបាទសម្តេចព្រះនរោត្តម

- ៣៨ -

(ហ្លួងសុវណ្ណកោដ្ឋ) នោះស្រុកយើងខ្មែរ ក៏មិនទាន់បានធំប៉ុណ្ណឹង ឯសៀមពីព្រោះតែបារាំងសែសគេសង្កិន បានជាវាប្រគល់ខេត្តបាត់ដំបង មង្គលបូរី ស៊ីសុផុន សៀមរាប ដែរនៅខាងម្ខាងទន្លេសាបទាំងប៉ុន្មានឲ្យយើងវិញ រីឯខេត្តកោះកុងដែរនៅត្រើយមាត់ស្រម៉ុទខាងលិច ក៏សៀមវាប្រគល់មកឲ្យយើងវិញដែរ ឯខេត្តទន្លេរពៅ ម្លូព្រៃ ដែរនៅជាខាងជើងនគរខ្មែរយើង ក៏សៀមវាប្រគល់មកឲ្យយើងវិញ ១ ទៀតស្រុកបារាំងសែសគេយកស្រុកលាវបានមកពីដៃសៀម ហើយគេប្រគល់ខេត្តស្ទឹងត្រែងមកឲ្យខ្មែរវិញ បើគ្មានស្រុកបារាំងសែសម្លេះសឹមយើងនិងយកខេត្តទាំងនោះ មកបញ្ចូលក្នុងស្រុកខ្មែរវិញមិនបានឡើយ កាលនៅក្នុង ៥០ ឆ្នាំមុន យើងមានបាបកម្មវាផ្តន្ទាយើង ឲ្យសូនឈ្មោះទៅជាចំណុះសៀម ហើយទីដីនគរយើងក៏ទៅជាដីសៀម រីឯសព្វថ្ងៃនេះខេត្តយើងក៏បានធំហើយរឹតតែធំឡើង ឯនគរយើងក៏ឡើងជាមហានគរធំ ដូច្នេះយើងមាន្តែខំមឧស្សាហ៍ធ្វើការបាត្តិប និងអាលបានឡើងស្មើរនិង

នាក់ស្រុកនគរធំនិងគេ ។ អើយើងបានមានបុណ្យស័ក្តិណាង ទាំងម្ល៉េះនេះដោយសារបារាំងសែស បើគ្មានគេប្រហែលជាយើង មិនកើតជាអ្វីសោះ សព្វថ្ងៃនេះបារាំងសែស គេមានគុណនឹងយើងបានជាយើងមានសិណាងបុណ្ណឹង ហេតុដូច្នេះទើបបានជាតាក៏គិតតែងជានិទានតាមរឿងដំណើរ ដែរមានរៀងមក ទុកទូន្មានបន្ទូលបិត្រអស់នាក់ទាំងពួង ដែរជាសាស្ត្រខ្មែរដូចគ្នា ឲ្យស្រឡាញ់រាប់អានទុកបិត្របារាំងសែស ដោយស្មោះត្រង់ កុំញ៉ើញឿតគិតរាមុក្ខរក្រោយឡើយ ដ្បិតបារាំងសែសនេះជាមិត្រមេត្រី ជាតិនិង ហើយជាគ្រូរយើងផង ។

សេចក្ដីដែរបានតែងជាបរិយាយ រឿងតាមដំណើរមកនេះ ផ្ទៀងខាតខុសលើសលោះ ឬពុំគោរម្យសមតីពីរោះរៀបទំរាញ អាត្ថសេចក្ដី សូមអស់លោកនាក់ទាំងឡាយអត្តោយទោស ដោយសារប្រាជ្ញាស្មារតីតិចបំណែះក៏ខ្សោយ ហើយខ្លួនក៏បាសជរាមាន តែចិត្តបរិសុទ្ធស្លូតត្រង់ ស្រឡាញ់ទឹកដីរបស់ខ្លួន ទើបតែង

តាមដំណើរទុកឲ្យចៅកូនក្រោយមើលស្តាប់តទៅ ព្រោះបិត្រសង្ឃឹមថាវត្ថារបារាំងសែស នឹងមកជាប់ចែងរៀបចំនគរយើង ឲ្យឡើងជានគរធំ មានបុណ្យអំណាចកូនចៅនៅឯក្រោយ គង់តែនឹងដឹងឮឃើញតទៅ បានជាតែងគិតធ្វើសេចក្ដីដូច្នេះ នេះព្រោះតែបិត្រខ្ញុំគិតតែខាងល្អ បើខុសកុំខុសសូមអភ័យទោស

តែងក្នុងចុលស័ករាជ ១២៦៩ ឆ្នាំមមែអេក្ខស័ក្ក កាលតាអាយុស្មបាន ៨០ ឆ្នាំហើយ ។:១